# កំណើតរដ្ឋបាលឃុំខ្មែរ

ដោយ អ៊ឹម មុន្នីចិន្តា

Shared By Chim Vanntha Laws Page

*រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលមានអាសនៈនៅក្នុងអង្គការសហប្រជាជាតិ និង អាស៊ាន (ASEAN) បានខិតខំរិះរកវិធានការ មធ្យោបាយដើម្បីរៀបចំអភិវឌ្ឍជាថ្មី នូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ ទាំងនៅលើផ្នែករដ្ឋបាល និងនៅលើគ្រប់វិស័យទាំងអស់ ។ ពិសេសដែលថ្មី ៗ នេះ រដ្ឋសភាកំពុងតែបើកកិច្ចប្រជុំពិភាក្សាអនុម័តនូវ ច្បាប់មួយចំនួន ដើម្បីបម្រើសង្គមជាតិទាំងមូលក្នុងនោះដែរ ក៏មានការពិភាក្សាទៅលើពង្រាងច្បាប់ស្តីពីការបោះឆ្នោតរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និង រដ្ឋបាលគ្រប់គ្រង ។ ឃុំ-សង្កាត់ផងដែរ ។*

*យ៉ាងណាមិញ ដើម្បីធ្វើការកែទម្រង់ និង អភិវឌ្ឍន៍ទៅលើវិស័យណាមួយនោះ គេគប្បីយល់ដឹងឲ្យបានច្បាស់ និងស៊ីជម្រៅទៅលើប្រវត្តិ និង រចនាសម្ព័ន្ធគ្រប់គ្រង ដែលបានកើតឡើងព្រមទាំងការអនុវត្តរបស់វិស័យនោះ ថាបានទទួលលទ្ធផលបែបណាដែរ ? និយាយរួមគឺបទពិសោធន៏ដែលបានទទួលពីប្រព័ន្ធមួយនោះ ។*

*តែនាពេលនេះ នាងខ្ញុំសូមលើកយកតែ "ប្រវត្តិរដ្ឋបាលឃុំខ្មែរ" មួយសិន មកបង្ហាញដល់អ្នកអានឲ្យបានជ្រាប ។ ដូចគ្នានេះដែរ នាងខ្ញុំសូមជម្រាបជូនលោក លោកស្រី អ្នកនាងកញ្ញាថាអត្ថបទខាងក្រោមនេះ គឺជាអត្ថបទសង្ខេប ហើយប្រសិនបើលោកលោកស្រីចង់ទទួលបាននូវការអធិប្បាយក្បោះក្បាយ ទាក់ទងទៅនឹង "រដ្ឋបាលឃុំខ្មែរ" នោះ សូមមេត្តាស្វែងរកអានសៀវភៅសារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រប្រវត្តិវិទ្យាជំនាន់ទី ១៨ របស់នាងខ្ញុំ ក្រោមប្រធានបទ "ប្រវត្តិនៃការវិវត្តរដ្ឋបាលឃុំខ្មែរ តាំងពីសម័យបុរាណរហូតមកដល់សម័យអាណាព្យាបាលបារាំង" ។*

## ១-ឃុំមុនបារាំងមកដល់

មុននឹងដាក់របបអាណាព្យាបាលនៅប្រទេសកម្ពុជា "*ឃុំ*" ប្រៀបដូចជាកុលសម្ព័ន្ធនៅក្នុងភូមិមួយ ប៉ុន្តែបណ្តាឃុំដែលមានរចនាសម្ព័ន្ធរួចហើយនោះ ពុំមែនមានលក្ខណៈច្បាស់លាស់ដូចទៅនឹងឃុំរបស់បារាំង ដែលបានរៀបចំនៅក្នុងប្រទេសកម្ពុជាកំឡុងឆ្នាំ ១៩០៨ នោះទេ គឺឃុំបារាំងមានលក្ខណៈជាអង្គភាពរដ្ឋបាលមួយបែបដោយឡែក ។ ដោយជាទូទៅ "*ឃុំ*" ពុំមានចែងជាលាយលក្ខណ៏អក្សរអ្វីទេ ហើយដែលគេយល់ឃើញថាមានច្បាស់នោះគឺរចនាសម្ព័ន្ធខេត្ត ដែលមានចៅហ្វាយខេត្ត (មន្ត្រីជាន់ខ្ពស់) ជាអ្នកដែលចាត់ចែងនូវរាល់កិច្ចការទាំងពួង ដោយធ្វើទំនាក់ទំនងទៅព្រះមហាក្សត្រ ។ ខេត្តនីមួយ ។ ចែកចេញជា "*ស្រុក*" ដែលស្ថិតនៅក្រោមការដឹកនាំរបស់ "*ចៅហ្វាយស្រុក*" ។ រីឯភូមិមួយ អាចដឹកនាំដោយ "*មេស្រុក*" ម្នាក់ ។ តាមធម្មតាមេស្រុកគឺជាមេកន្ត្រាញ ហើយដែលជាអ្នកតំណាងរបស់ចៅហ្វាយស្រុក ដែលមានអំណាចខ្ពស់ជាងខ្លួន ។

ដោយប្រការខាងលើនេះហើយ ទើបធ្វើឲ្យបារាំងមានគំនិតស្មានថា "*ឃុំ*" ដូចទៅនឹង "*មែរ*" (le maire) របស់គេ ទើបគិតកែឆ្នៃទៅតាមរបៀបច្បាប់បារាំងសម័យនោះបន្តិចម្តង ។ ។ "*មេស្រុក*" ខ្មែរសម័យបុរាណ ជាបុរសស្វាហាប់ អាយុក្មេងល្មមធ្វើការបាន និងត្រូវបានជ្រើសតាំងឡើងដោយក្រុមពួកចាស់ទុំក្នុងស្រុកដែលពេលនោះ "*ស្រុក*" មានន័យថា "*ភូមិកំណើត*" ហើយមិនមែនមានន័យដូច "*ស្រុក*" ក្នុងវិស័យរដ្ឋបាលសព្វថ្ងៃនេះទេ ។

ក្រុមពួកចាស់ទុំនោះ គេហៅថា "*ក្រុមជំនុំពួកចាស់ទុំ*" ប្រហែលជាដូចពាក្យថា "*គ្រាមវ្ទ្ធ*"=ព្រឹទ្ធាចារ្យរបស់ភូមិ ឬព្រឹទ្ធាចារ្យនៅក្នុងភូមិ ដែលមាននៅក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ ។ អ្វីដែល "*ក្រុមជំនុំ*" បានសម្រេច គេប្រគល់ឲ្យអ្នកជំនួយការ "*មេស្រុក*" ជាអ្នកប្រតិបត្តិ ។ "*មេស្រុក*" ធ្វើការឥតមានប្រាក់កម្រៃអ្វីទាំងអស់ ប៉ុន្តែគេទទួលផលពីការស្រឡាញ់រាប់អាន ដឹងគុណពីអ្នកស្រុក និងទទួលអំណោយ ដែលអ្នកស្រុកស្ម័គ្រចិត្តឲ្យ ។ ប្រព័ន្ធរដ្ឋបាលនេះ ជាប្រព័ន្ធ "*ព្រឹទ្ធ*" គឺគេគោរពចាស់ទុំ ធ្វើតាមបញ្ជានិងយោបល់របស់ចាស់ទុំ ។ ដោយហេតុថា មានអតីតមន្ត្រី អាចារ្យ និង អ្នកប្រាជ្ញអក្សរសាស្ត្រ ចូលរួមគិតកិច្ចការក្នុងស្រុកផងនោះ ក្រោយមក "*ក្រុមជំនុំ*" បានប្រែក្លាយទៅជា "*ក្រុមពញា*" វិញ ។ "*ក្រុមពញា*" ជាអ្នករើសអ្នកជំនួយការងារមេស្រុក ហើយដាក់ឈ្មោះថា "*ជំទប់*" រីឯជំទប់ទៀតសោតអាចរកស្មៀនឲ្យជួយសរសេរ និងធ្វើការងារផ្សេង ។ បាន ។ អ្នកទាំងអស់នេះធ្វើការដោយគ្មានយកប្រាក់ខែអ្វីទាំងអស់ ពីព្រោះ "*ប្រាក់សម្រាប់ចាយ*" ទើបតែបង្កើតឡើងដោយព្រះបាទអង្គឌួង នាពាក់កណ្តាលសតវត្សរ៏ទី ១៩ នេះទេ ។ ជំទប់គេទទួលតែអំណោយដូចជារង្វាន់ត្រី ដូង ផ្លែឈើ បន្លែ ។ល។

រីឯនៅពេលបារាំងមកដល់ ក៏ប្រើ "*មេស្រុក*" ឲ្យទារពន្ធដារជូនរាជការ (ឲ្យបារាំង) ដូច្នេះ គ្មានអ្នកណាចង់ធ្វើមេស្រុកឲ្យបារាំងឡើយ ។ បន្ទាប់មក បារាំងបានបញ្ចូលគោលការណ៏បោះឆ្នោតរើស "*មេស្រុក*" និង រើស "*ក្រុមជំនុំ*" នៅឆ្នាំ ១៩០១ និង ១៩០២ ដោយមានបញ្ចូលនូវគោលការណ៏ផ្តល់ប្រាក់កម្រៃជាភាគរយដល់មេស្រុកមិនតែប៉ុណ្ណោះ ថែមទាំងបន្ថែមអំណាចដល់មេស្រុកទៀតផង គេធ្វើបែបនេះក្នុងគោលបំណងបង្កើនប្រសិទ្ធិភាពក្នុងការទារពន្ធដារ ។ "*ប្រាក់ និង បុណ្យសក្តិ*" ដែលអាណាព្យាបាលបារាំងបំពាក់ឲ្យមេស្រុកនេះ ធ្វើឲ្យ "*មេស្រុក*" ដែលក្នុងន័យដើមជាអ្នកបម្រើរាស្ត្រ ហើយដែលរាស្ត្រស្រឡាញ់ ក្លាយទៅជាភ្នាក់ងារស៊ីឈ្នួលបារាំង

សង្កត់កខ្មែរគ្នាឯងវិញ ។

ក្នុងន័យរដ្ឋបាល ពាក្យ “*មេស្រុក*” បញ្ជាក់ថា ជាមេឃុំ ហើយដែលត្រូវបានគេប្រើមុនឆ្នាំ ១៩០៨ ប៉ុន្តែដោយការនិយមប្រើជាយូរមកហើយ ពាក្យនេះក៏ត្រូវបានគេប្រើរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៦០ តែទាំងនេះ គឺគ្មានការបញ្ជាក់ទាល់តែសោះ អំពីការបែងចែករដ្ឋបាលកណ្តាលរវាងខេត្ត និង ភូមិ ។ ក្នុងនោះដែរ នៅឆ្នាំ ១៩០១ គេបានបង្កើតឲ្យមានក្រុមប្រឹក្សាស្រុកមួយ (un conseil du srok) ដែលរួមមាន មេស្រុក ជំទប់ និង ណូតាប្លូ notable* ២ នាក់ ។ ក្រុមប្រឹក្សានេះ ត្រូវនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មេស្រុក និង ក្រោមការទទួលខុសត្រូវខ្ពស់របស់ចៅហ្វាយស្រុក ដោយមាននាទីទទួលខុសត្រូវចំពោះកិច្ចការពន្ធដារ ។ “*មេស្រុក*” គឺជាអ្នកបង្កើតឲ្យមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅរវាងថ្នាក់លើ និង ប្រជាជន ។

ចំពោះការបោះឆ្នោតរើស “*មេស្រុក*” និង “*ក្រុមជំនុំ*” វិញ វាហាក់បីដូចជាពុំមានលក្ខណៈច្បាស់លាស់ និង សុក្រឹតសោះ គឺបារាំង ចង់តែផ្លាស់ប្តូរ “*មេស្រុក*” មុន ។ នោះចេញប៉ុណ្ណោះ។ តែដល់ក្រោយឆ្នាំ ១៩០២ គេក៏មិនឮនិយាយអំពី “*ការសាកល្បងរៀបចំឃុំខ្មែរ*” ទៀតដែរ ដោយគ្រាន់តែបញ្ជាក់ថា ឃុំមិនមានទៀតទេ ហើយគេត្រូវបង្កើតមូលដ្ឋានចាំបាច់ និង រឹងមាំ ហើយមានលក្ខណៈទូទៅដើម្បីរៀបចំឃុំជាថ្មី ។

## ២-កំណើតរដ្ឋបាលឃុំ

រហូតមកដល់ឆ្នាំ១៩០៨បារាំងបានប្តូរឈ្មោះ“*ស្រុក*”ទៅ ជា “*ឃុំ*” ហើយ “*មេស្រុក*” ទៅជា “*មេឃុំ*” ដែលរាស្ត្រខ្លាច និង ស្អប់ ។ ដោយឃើញថាកង្វះការសហការពីរាស្ត្រ បារាំងក៏ធ្វើឲ្យមានការបោះឆ្នោតជាសកលដើម្បីរើសមេឃុំ និង ក្រុមជំនុំ ហើយធ្វើឲ្យឃុំមានថវិកាផ្ទាល់ខ្លួននៅក្នុងឆ្នាំ ១៩១៩ ។ ថវិកាឃុំជានុយទាក់ទាញឲ្យបានចំណូលពន្ធដារបានច្រើន ។ ប៉ុន្តែការធ្វើបែបនេះនៅតែមិនទទួលបានលទ្ធផលល្អ ដោយរាស្ត្រមិនសូវសហការ និង រាស្ត្រកាន់តែមានបន្ទុកបន្ថែមដែលបណ្តាលឲ្យជីវភាពកាន់តែយ៉ាប់យ៉ឺន ។ គេបង្កើតឲ្យមាន ថវិកាឃុំ ប៉ុន្តែគេដឹងច្បាស់ថាមេឃុំគ្មានសមត្ថភាព ដូច្នេះអ្វី ។ វានៅតែក្នុងកណ្តាប់ដៃរបស់អ្នកតំណាងអំណាចកណ្តាល (រដ្ឋាភិបាល) ដដែល ជាដដែល ។ បើគិតទៅពីឆ្នាំ ១៨៨៩ ដល់ឆ្នាំ ១៩៥៣ រដ្ឋបាលអាណាព្យាបាលបារាំងបានធ្វើកំណែទម្រង់រដ្ឋបាល ឃុំធំ ។ ៨ លើក ប៉ុន្តែពុំមានប្រសិទ្ធិភាពអ្វីសោះ ហើយពីដំណាក់កាលមួយទៅដំណាក់កាលមួយ យើងឃើញថា គឺសុទ្ធតែមានចេញ នូវព្រះរាជប្រកាស ដើម្បីរៀបចំនូវបណ្តាឃុំទាំងនោះ ដូចគ្នានេះដែរ ក៏មានបង្ហាញឲ្យឃើញថា រដ្ឋបាលសម័យនោះ ធ្វើឡើងតាមបែប វិមជ្ឈការផង និង មជ្ឈការផង ។

បន្ទាប់ពីខែមករា ឆ្នាំ ១៩២៦ ដល់ឆ្នាំ ១៩៤៣ ឃុំមានមុខងារក្នុងលក្ខខណ្ឌនៃច្បាប់យ៉ាងពិតប្រាកដដូចឃុំរបស់បារាំងដែរ ។ ប៉ុន្តែ អ្វីដែលគួរឲ្យស្តាយនោះ គឺប្រព័ន្ធបោះឆ្នោតឃុំត្រូវលុបបំបាត់ចោលក្រោយពីមានការរៀបចំឃុំឡើងវិញនៅឆ្នាំ ១៩៤៣ ។ មេឃុំ និង ជំទប់ត្រូវបានតែងតាំងដោយអភិបាលខេត្ត (ចៅហ្វាយខេត្ត) ដោយមានការយល់ព្រមពីរ៉េស៊ីដង់បារាំង ។ ចាប់តាំងពីមានក្រិត្យលេខ ៥៣ នស និង ៤០ នស ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ១៩៤១ និង ខែកក្កដា ឆ្នាំ ១៩៤៣ មក ឃុំត្រូវបានបែងចែកជាពីរប្រភេទដោយផ្អែកទៅលើឋានៈ និង ទំហំការងារដែលឃុំខ្លះក្រុមប្រឹក្សាឃុំបានមកពីការតែងតាំង និង ក្រុមប្រឹក្សាខ្លះទៀតបានមកពីការបោះឆ្នោតជ្រើសរើស ។ ឃុំសំខាន់ ឬឃុំដែលមានទំហំធំជាងគេ ការបោះឆ្នោតត្រូវផ្អាក ឬព្យួរ ចំណែកឃុំមិនសូវសំខាន់ ឬឃុំតូច គេអនុញ្ញាតឲ្យធ្វើការបោះឆ្នោត តែការណ៍នេះ គេពុំឃើញមានការអនុវត្តទេ ។ ម្យ៉ាងទៀតតាមគោលការណ៍ច្បាប់ ទោះបីជាមានកន្លែងទំនេរក្នុងរយៈពេលនៃការកាន់តំណែងរបស់មេឃុំក៏ដោយ ក៏គេពុំមានសិទ្ធិជ្រើសតាំងមេឃុំជំនួសកន្លែងនោះដែរ គឺត្រូវចាំរហូតទាល់តែដាច់អាណត្តិរបស់មេឃុំរូបនោះសិន និងត្រូវជ្រើសឡើងតាមរយៈការបោះឆ្នោតជាចាំបាច់ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គ្រប់កន្លែង (កៅអីរបស់មេឃុំ) ទំនេរទាំងអស់ ត្រូវបំពេញដោយការតែងតាំងទៅវិញ ។ រហូតដល់ឆ្នាំ ១៩៥៥ មានសារាចរណែនាំមួយស្នើសុំឲ្យមានការបោះឆ្នោតមេឃុំ តែការអនុវត្តនៅតាមបណ្តាខេត្ត នីមួយ ។ មានលក្ខណៈផ្សេង ។ គ្នា ។

សរុបទៅឃុំបានចាប់បដិសន្ធិនៅក្នុងសង្គមខ្មែរតាំងពីឆ្នាំ ១៩០៨ មកម្ល៉េះ គ្រាន់តែថា ពុំសូវមានលក្ខណៈពេញលេញ និងមិនបានស្ថិតស្ថេរ ។ រីឯការរៀបចំឲ្យមានរដ្ឋបាលឃុំឡើង គឺបានធ្វើឲ្យមានការកែប្រែរដ្ឋបាលសាធារណៈដ៏ធំមួយ នៅក្នុងប្រទេសកម្ពុជា ៕

---

* notable : *ក្រុមការ ជាងារក្នុងតំណែងរាជការឃុំសម័យដើម ។*